01739791

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

# គម្រោងបញ្ចប់ផែនការ

## កំណែលើកទី៣

## ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤


**សេចក្តីសង្ខេប** .......... 2

I. **សេចក្តីផ្តើម** .......... 2

II. **វិធានការដែលអាចជួយបញ្ចប់ផែនការបានឆាប់រហ័ស** .......... 9

III. **ផែនការបញ្ចប់ការស៊ើបអង្កេត** .......... 12

IV. **ផែនការបញ្ចប់សវនាការ** .......... 14

ក. សំណុំរឿង០០២/០១ .......... 15

ខ. សំណុំរឿង០០២/០២ .......... 16

គ. បទចោទដែលនៅសេសសល់/ការចោទប្រកាន់តាមអង្គហេតុក្នុងសំណុំរឿង០០២ .......... 19

ឃ. សំណុំរឿង០០៣ និង សំណុំរឿង០០៤ .......... 20

V. **ផែនការបញ្ចប់បណ្តឹងសាទុក្ខ** .......... 20

ក. សំណុំរឿង០០២/០១ .......... 21

VI. **សេចក្តីសន្និដ្ឋាន** .......... 24


ឧបសម្ព័ន្ធ ៖ តារាងកំណត់ពេលវេលាតាមការគ្រោងទុកសម្រាប់ការបញ្ចប់ផែនការ ដែលរួមមានគ្រោងការសំខាន់ៗផង។

01739792

## សេចក្តីសង្ខេប

គម្រោងបញ្ចប់ផែនការសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះ”) បាន រៀបចំឡើងនៅខែ មីនា ឆ្នាំ ២០១៤ ដោយឆ្លងកាត់ការពិគ្រោះពិភាក្សាយោបល់ពីសំណាក់ការិយាល័យ រដ្ឋបាល ជាមួយនឹងចៅក្រមនៃអង្គជំនុំជម្រះ សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា ទាក់ទិននឹងការទទួលខុសត្រូវរបស់ពួកគាត់។ នេះគឺជាបច្ចុប្បន្នភាពប្រចាំត្រីមាសទី៣នៃគម្រោងបញ្ចប់ ផែនការដែលផុតនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤។

ចាប់តាំងពីត្រីមាសចុងក្រោយនៃការបញ្ចប់ផែនការនេះ អង្គជំនុំជម្រះវិសាមញ្ញបានសម្រេចនូវ ព្រឹត្តិការណ៍សំខាន់២ ពោលគឺការចាប់ផ្តើមដំណាក់កាលសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ នៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ និងការដាក់សារណាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង សំណុំរឿង០០២/០១របស់សហព្រះរាជអាជ្ញា នៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ និងរបស់ក្រុម មេធាវី នួន ជា និង ខៀវ សំផន នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤។

លំហូរនៃគម្រោងបញ្ចប់ផែនការនេះត្រូវបានធ្វើបច្ចុប្បន្នភាព ក្នុងគោលបំណងដើម្បីឆ្លុះបញ្ចាំងអំពី ស្ថានភាពនៃដំណើរការនីតិវិធីតុលាការគិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤។

## I. សេចក្តីផ្តើម

១ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អង្គជំនុំជម្រះវិសាមញ្ញ”) បានចាប់ផ្តើមដំណើរការរបស់ ខ្លួននៅខែកុម្ភៈ ឆ្នាំ២០០៦ និងបានដំណើរពេញលេញបន្ទាប់ពីការអនុម័តវិធានផ្ទៃក្នុងនៅក្នុងខែមិថុនា ឆ្នាំ២០០៧។ អណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បីកាត់សេចក្តី “មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជា ធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរ ទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការ រំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី

១៧ ខែ មេសា ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ១៩៧៩”[1]។ នៅក្នុងរបាយការណ៍មួយ ដែលបានដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិនៅខែ មីនា ឆ្នាំ ២០០៣ អគ្គលេខាធិការ ដំបូងឡើយបានបង្ហាញថា អាណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញ មានរយៈពេលបីឆ្នាំ ដើម្បីបញ្ចប់ការជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលទាំងអស់ “នៅពេលដែលការិយាល័យរបស់សហព្រះរាជអាជ្ញា បានចាប់ផ្ដើមប្រតិបត្តិការរបស់ខ្លួន”[2]។ តារាងកំណត់ពេលវេលាត្រូវបានកែប្រែចាប់តាំងពីពេលនោះមក ហើយអគ្គលេខាធិការបានជូនដំណឹងជាផ្លូវការដល់មហាសន្និបាតអង្គការសហប្រជាជាតិនៅខែ តុលា ឆ្នាំ ២០១៣ ថា តារាងកំណត់ពេលវេលារបស់អង្គជំនុំជម្រះវិសាមញ្ញ “មានគម្រោងសកម្មភាពតុលាការរហូតដល់ឆ្នាំ២០១៨ និងអាចបន្តហួសពីពេលវេលាកំណត់នេះទៅទៀត”[3]។

២ គម្រោងបញ្ចប់ផែនការនេះបានបរិយាយយ៉ាងលម្អិតដោយ អ.វ.ត.ក ក្នុងបរិបទនៃសេចក្ដីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ A/RES/68/247B ដែលក្នុងចំណោមបញ្ហាផ្សេងៗទៀតបានកំណត់អាណត្តិរបស់ អ.វ.ត.ក ឲ្យរៀបចំយុទ្ធសាស្ត្របញ្ចប់ ដោយមានផែនទីបង្ហាញផ្លូវច្បាស់លាស់មួយ[4]។ ឯកសារនេះធ្វើឡើងដោយ អ.វ.ត.ក ដោយមានការពិគ្រោះយោបល់តាមរយៈការិយាល័យរដ្ឋបាលជាមួយចៅក្រមអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាអំពីការទទួលខុសត្រូវរបស់ពួកគេ។ អ.វ.ត.ក គិតទុកជាមុនថានៅពេលខាងមុខខ្លួននឹងធ្វើបច្ចុប្បន្នភាពផែនការបញ្ចប់នេះរៀងរាល់ត្រីមាស។ ឯកសារនេះគឺជាកំណែលើកទី៣ប្រចាំត្រីមាសនៃគម្រោងបញ្ចប់ផែនការ ហើយបានបញ្ចូលនូវការកែ

---

[1] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

[2] របាយការណ៍របស់អគ្គលេខាធិការស្ដីពីការជំនុំជម្រះខ្មែរក្រហម ឯកសារ A/57/769 កថាខណ្ឌ៥៦។

[3] សំណើសុំឧបត្ថមធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឯកសារ A/68/532 កថាខណ្ឌ៣៨។

[4] នៅក្នុងសេចក្ដីសម្រេចដដែលនោះ មហាសន្និបាត អ.ស.ប បានស្នើឲ្យមាន “ការពិនិត្យយ៉ាងម៉ត់ចត់ទៅលើការផ្ដល់ហិរញ្ញប្បទានសម្រាប់ អ.វ.ត.ក នៅពេលអនាគតសម្រាប់ឆ្នាំ ២០១៥ និងឆ្នាំខាងមុខទៀត”។ សូមមើលសេចក្ដីសម្រេចលេខ A/RES/68/247B ដែលអនុម័តដោយមហាសន្និបាត អ.ស.ប នៅថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៤។ “កម្មវត្ថុពិសេសនានាទាក់ទិននឹងថវិកាសម្រាប់កម្មវិធីរយៈពេល២ឆ្នាំម្ដង ២០១៤-២០១៥” B, I, កថាខណ្ឌទី៨។

01739794

តម្រូវដែលចាំបាច់នានា ដោយផ្អែកលើការវិវត្តនៃដំណើរការនីតិវិធីតាមផ្លូវតុលាការដែលកំពុងប្រព្រឹត្តទៅក្នុងរវាងថ្ងៃទី ១ ខែ តុលា ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤។

៣ ឯកសារនេះផ្តោតជាពិសេសលើការវិវត្តន៍នាពេលថ្មីៗនេះ នៅក្នុងសំណុំរឿងទាំងបីដែលបច្ចុប្បន្នកំពុងស្ថិតនៅចំពោះមុខ អ.វ.ត.ក និងផ្តល់នូវព័ត៌មានអំពីប្រភេទនៃរឿងក្តី ព្រមទាំងស្ថានភាពនៃសំណុំរឿងទាំង នោះព្រមទាំងជំហាននានាដែលត្រូវបំពេញ មុនពេលកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការទាក់ទិន នឹងសំណុំរឿងកំពុងរង់ចាំបច្ចុប្បន្ននៅចំពោះមុខ អ.វ.ត.ក អាចនឹងបញ្ចប់ជាស្ថាពរតាមផ្លូវច្បាប់។

៤ អង្គជំនុំជម្រះវិសាមញ្ញបានបញ្ចប់ជាស្ថាពរនូវកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០១ ប្រឆាំងនឹង កាំង ហ្គេកអ៊ាវ ហៅឌុច នៅពេលដែលអង្គជំនុំជម្រះតុលាការកំពូលបានចេញសាលដីការបស់ខ្លួនលើបណ្តឹងសាទុក្ខ កាលពីថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២។ កាំង ហ្គេកអ៊ាវ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត និងត្រូវបានបញ្ជូនទៅពន្ធនាគារខេត្តកណ្តាល កាលពីថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១៣ ដើម្បីអនុវត្តទោសដែលនៅសល់។

៥ បច្ចុប្បន្ននេះ អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង០០២ ដែលជាការជំនុំជម្រះរួមលើ ខៀវ សំផន និង នួន ជា។ ជនជាប់ចោទទីបី ឈ្មោះ អៀង សារី បានទទួលមរណភាពកាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ ហើយកិច្ចដំណើរការនីតិវិធីលើរូបគាត់ ត្រូវបានបញ្ចប់នៅថ្ងៃនោះផងដែរ។ ជនជាប់ចោទទីបួន ឈ្មោះ អៀង ធីរិទ្ធ ត្រូវបានរកឃើញថាមិនមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមនៅក្នុងសវនាការ ដោយសារតែស្ថានភាពជំងឺវង្វេងស្មារតីកាន់តែធ្ងន់ធ្ងរ ហើយកិច្ចនីតិវិធីលើរូបគាត់បច្ចុប្បន្ននេះត្រូវបានព្យួរតាមរយៈការផ្អាកកិច្ចនីតិវិធីជាផ្លូវការ។ គាត់នៅតែស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការដដែល។ គាត់មិនត្រូវបានអនុញ្ញាតឲ្យចាកចេញពីប្រទេសកម្ពុជា ដោយគ្មានការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូង គាត់មិនអាចផ្លាស់ប្តូរអាសយដ្ឋានស្នាក់នៅដោយមិនជូនដំណឹងជាមុន នោះទេ ហើយអាណាព្យាបាលស្របច្បាប់របស់គាត់ ត្រូវផ្តល់របាយការណ៍ប្រចាំខែដើម្បីបញ្ជាក់អំពីការអនុវត្តលក្ខខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការ។ អៀង ធីរិទ្ធ ក៏ត្រូវទទួលបានការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រពីរដងក្នុងមួយឆ្នាំ ដើម្បីវាយតម្លៃថាតើមានការប្រែប្រួលណាមួយទៅលើសមត្ថភាពបញ្ញាស្មារតី ដែលអាចប៉ះពាល់ដល់សម្បទារបស់គាត់ក្នុងការចូលរួមសវនាការផងដែរ។

01739795

៦ មកដល់ពេលនេះអង្គជំនុំជម្រះបានបំបែកបទចោទនៅក្នុងសំណុំរឿង០០២ ទៅជាសវនាការតូចៗ ចំនួនពីរ ។ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមនៅក្នុងសវនាការដំណាក់កាលទីមួយ ដែល អ.វ.ត.ក កំណត់ឈ្មោះ សំណុំរឿងថា សំណុំរឿង០០២/០១នៅថ្ងៃទី ៧ ខែសីហា ឆ្នាំ២០១៤។ ខៀវ សំផន និង នួន ជា ត្រូវបានរកឃើញថាមានពិរុទ្ធភាពពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ដែលប្រព្រឹត្ត ក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៧ និង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ អស់មួយជីវិត។ ទាំង នួន ជា និង ខៀវ សំផន បានដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសាលា ដំបូង ក្នុងសំណុំរឿង០០២/០១។ សហព្រះរាជអាជ្ញាក៏បានដាក់បណ្តឹងសាទុក្ខកម្រិតត្រឹមតែស្នើសុំ សេចក្តីប្រកាសជាប្រយោជន៍ទៅលើការអនុវត្តទម្រង់ទូលាយបំផុតនៃសហឧក្រិដ្ឋកម្មរួមដែលហៅថា JCEIII ជាទម្រង់ទទួលខុសត្រូវមួយនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ។

៧ ការជំនុំជម្រះទីពីរកំពុងដំណើរការក្នុងពេលបច្ចុប្បន្ននេះ ដែល អ.វ.ត.ក ដាក់ឈ្មោះថា សំណុំរឿង ០០២/០២ គឺផ្តោតលើជម្រើសតំណាងបទចោទមួយចំនួនដែលនៅសល់ប្រឆាំងនឹងជនជាប់ចោទទាំង ពីរនាក់។ អង្គជំនុំជម្រះសាលាដំបូងបង្គាប់ថា សវនាការនេះនឹងចាប់ផ្តើមដំបូងជាមួយនឹងបទចោទ ពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់ ក្នុងនោះរួមមានការប្រព្រឹត្តមកលើ ពុទ្ធសាសនិក និងពាក់ព័ន្ធនឹង មន្ទីរសន្តិសុខក្រាំងតាចាន់។ ដំណាក់កាលក្រោយមកទៀត សវនាការ នឹងផ្តោតលើបទចោទនានា ពាក់ព័ន្ធនឹងការដ្ឋានជាក់លាក់ចំនួន៣។ បន្ទាបមកទៀត សវនាការនឹង ពិចារណាលើការប្រព្រឹត្តមកលើ ក្រុមគោលដៅ (ជនជាតិចាម និងវៀតណាម) មន្ទីរសន្តិសុខបន្ថែមទៀត និងការបោសសម្អាតផ្ទៃក្នុង បទប្បញ្ញត្តិនៃការរៀបអាពាហ៍ពិពាហ៍ លក្ខណៈនៃជម្លោះប្រដាប់អាវុធ និងតួនាទីរបស់ជនជាប់ចោទ។ បច្ចុប្បន្ន អង្គជំនុំជម្រះសាលាដំបូងកំពុងតែពិនិត្យទៅលើបញ្ជីឈ្មោះបុគ្គលដែលត្រូវ មកផ្តល់សក្ខីកម្ម ពាក់ព័ន្ធនឹងប្រធានបទនីមួយៗនៃការជំនុំជម្រះក្តី ហើយកំពុងវាយតម្លៃទៅលើភាពអាចទទួលយក បាននៃឯកសារនានាដែលភាគីបានស្នើថាមានភាពពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធី។ សវនាការ លើអង្គសេចក្តីក្នុងការជំនុំជម្រះក្តីនេះបានចាប់ផ្តើមនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤។ អង្គជំនុំជម្រះ សាលាដំបូងបានស្តាប់សេចក្តីថ្លែងចោទប្រកាន់របស់សហព្រះរាជអាជ្ញាជាតិ និង សហព្រះរាជអាជ្ញា អន្តរជាតិ។ បន្ទាប់មក ខៀវ សំផន និង នួន ជា បានបង្ហាញភាពមិនពេញចិត្តចង់ចូលរួមក្នុងកិច្ចនីតិវិធី ក្នុងសំណុំរឿង០០២/០២ លុះត្រាតែមានដំណោះស្រាយទៅលើបញ្ហាជាក់លាក់នានា ហើយ បាន បង្គាប់ឲ្យមេធាវីការពារក្តីរបស់ខ្លួនអនុវត្តទៅតាមការណែនាំរបស់ខ្លួន។ មេធាវីការពារក្តី នួន ជា

ត្រឡប់មកកាន់សាលសវនាការវិញនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤ ប៉ុន្តែ មេធាវីការពារក្តី ខៀវ សំផន បន្តអវត្តមានដែលជាការរំលោភបំពានដោយផ្ទាល់ទៅនឹងដីកាបង្គាប់របស់អង្គជំនុំជម្រះ។ ជាលទ្ធផល អង្គជំនុំជម្រះសាលាដំបូងបានបង្ខំចិត្តផ្អាកការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីសវនាការលើភស្តុតាងក្នុង សំណុំរឿង០០២/០២ រហូតដល់ថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥។ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា កំហុសវិជ្ជាជីវៈរបស់មេធាវីការពារក្តី ខៀវ សំផន គឺជាការរាំងស្ទះដល់កិច្ចដំណើរការនីតិវិធី និង បានបញ្ជូនករណីកំហុសវិជ្ជាជីវៈនេះទៅអង្គភាពមានសមត្ថកិច្ចរបស់មេធាវីទាំងពីរក្រុម ដើម្បីដាក់ ទណ្ឌកម្ម។ ទោះបីជាអង្គជំនុំជម្រះបានពិចារណាដាក់ផ្លាស់ប្តូរមេធាវីរបស់ ខៀវ សំផនក៏ពិតមែន ប៉ុន្តែ អង្គជំនុំជម្រះបានសន្និដ្ឋានថា ពេលវេលាក្នុងការចាត់តាំងមេធាវីថ្មីដែលចាំបាច់ត្រូវសិក្សាសំណុំរឿង នោះវានឹងនាំដល់ការពន្យារកិច្ចនីតិវិធីបន្ថែមទៀត។ ប្រសិនបើមេធាវីការពារក្តីសម្រេចធ្វើឱ្យ រាំងស្ទះ ដល់ កិច្ចដំណើរការនីតិវិធីនៅពេលអនាគត ពួកគេនឹងត្រូវជំនួសដោយមេធាវីការពារក្តីប្រចាំការ ដែល អង្គជំនុំជម្រះបង្គាប់ចាត់តាំងនៅក្នុងសេចក្តីសម្រេច ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៤។

៨ សំណុំរឿង០០៣ និង ០០៤ បច្ចុប្បន្ននេះ កំពុងស្ថិតនៅក្នុងដំណាក់កាលស៊ើបអង្កេត។ សហចៅក្រម ស៊ើបអង្កេតអន្តរជាតិ កំពុងស៊ើបអង្កេតសំណុំរឿងទាំងពីរនេះយ៉ាងសកម្ម ដែលពាក់ព័ន្ធនឹងការចោទ ប្រកាន់លើជនសង្ស័យចំនួនប្រាំរូប[5]។ គ្មានជនសង្ស័យណាម្នាក់ត្រូវបានចាប់ខ្លួន ឬចោទប្រកាន់ជាផ្លូវ ការនោះទេ ហើយអត្តសញ្ញាណរបស់ពួកគេ នៅតែរក្សាជាសម្ងាត់។ នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សេចក្តីសន្និដ្ឋានបន្ថែមមួយ ដែលស្នើជាផ្លូវការឱ្យសហ ចៅក្រម ស៊ើបអង្កេតពង្រីកកិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ ដើម្បីបញ្ចូលការចោទប្រកាន់ពីបទការ រៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និង រំលោភសេពសន្ថវៈ[6]។

៩ មានការរំពឹងថា សេចក្តីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ អាចនឹងចេញនៅ ត្រីមាសទី១នៃឆ្នាំ២០១៥ ហើយសេចក្តីសម្រេចមួយ ក្នុងទម្រង់ជាដីកាដំណោះស្រាយ ថាតើនឹង ត្រូវចោទប្រកាន់ និងបញ្ជូនទៅជំនុំជម្រះ ឬយ៉ាងណានោះ នឹងចេញនៅត្រីមាសទី៣ ឆ្នាំ២០១៥។

---

[5] សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៩ (www.eccc.gov.kh/sites/default/files/media/ECCC_Act_Int_Co_Prosecutor_8_Sep_2009_(Eng).pdf)។

[6] សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹងសំណុំរឿង០០៤ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ (http://www.eccc.gov.kh/sites/default/files/media/ECCC%20OCP%20PR%204%20Nov%202014%20Eng.pdf)។

01739797

១០ ដោយហេតុថាមានការខុសប្លែកគ្នានៃស្ថានភាពស៊ើបអង្កេតប្រឆាំងនឹងជនសង្ស័យបីនាក់ក្នុងសំណុំរឿង ០០៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កំពុងតែពិចារណាលើជម្រើសចំនួន២៖ ក) សំណុំរឿង០០៤ អាចនឹងត្រូវបំបែក ដែលក្នុងករណីនេះ សេចក្តីជូនដំណឹងចំនួន២ អំពីការបញ្ចប់កិច្ចស៊ើបសួរអាចនឹង ចេញនៅក្នុង ត្រីមាសទី១ នៃឆ្នាំ២០១៥ ហើយសេក្តីជូនដំណឹងទី៣ នឹងចេញនៅត្រីមាសទី២ ខ) ជម្រើសម្យ៉ាងទៀត សំណុំរឿង០០៤អាចស្ថិតនៅក្នុងទម្រង់ដដែល ដែលក្នុងករណីនេះ កិច្ចស៊ើប សួរអាចបញ្ចប់នៅត្រឹមត្រីមាសទី២ ឆ្នាំ២០១៥។ ប្រសិនបើសំណុំរឿង០០៤ ត្រូវបានបំបែក គឺមានការ ប៉ាន់ស្មានថាដីកាដំណោះស្រាយ អាចចេញនៅក្នុងត្រីមាសទី២ ត្រីមាសទី៣ និងត្រីមាសទី៤ ឆ្នាំ២០១៥។ ប្រសិនបើសំណុំរឿង០០៤ មិនត្រូវបានបំបែក មានការប៉ាន់ស្មានថា សេចក្តីសម្រេចមួយ នឹងចេញនៅត្រីមាសទី៤ ឆ្នាំ២០១៥ នៅក្នុងទម្រង់នៃដីកាដំណោះស្រាយ ថាតើនឹងត្រូវចោទប្រកាន់ ហើយបញ្ជូនទៅជម្រះចំពោះជនសង្ស័យណាមួយ(ឬជនសង្ស័យណាខ្លះ) ។

១១ សហព្រះរាជអាជ្ញា បានលើកឡើងជាសាធារណៈថា បន្ទាប់ពីសំណុំរឿង០០៣ និង០០៤ នឹងលែងមាន សំណុំរឿងបន្ថែមទៀតហើយ[7]។ ចំនួនសំណុំរឿង ដែលមានបច្ចុប្បន្នគឺជាចំនួនសំណុំរឿងសរុបដែល នឹងត្រូវដោះស្រាយដោយ អ.វ.ត.ក។

១២ តាមរយៈការវិវត្តន៍ក្នុងត្រីមាសចុងក្រោយនេះ គម្រោងបញ្ចប់ផែនការរបស់អង្គជំនុំជម្រះវិសាមញ្ញ មានគ្រោងការសំខាន់ចំនួន១៥សម្រាប់សំណុំរឿងចំនួនបីដែលអង្គជំនុំជម្រះនានាបានទទួល។ គ្រោងការសំខាន់ដែលនៅសេសសល់នៅក្នុងសំណុំរឿង០០២[8] និង ការព្យាករណ៍ ដែលពាក់ព័ន្ធគឺ៖

(i) ការចាប់ផ្តើមសវនាការលើភស្តុតាងក្នុងសំណុំរឿង០០២/០២ (ថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥)

---

[7] សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី - ការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីចំនួនពីរ ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៩ (www.eccc.gov.kh/sites/default/files/media/ECCC_Act_Int_Co_Prosecutor_8_Sep_2009_(Eng).pdf) ។ សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាទាក់ទិននឹងការស៊ើបអង្កេតនៅក្នុងសំណុំរឿង០០៣ ថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០១២ (www.eccc.gov.kh/sites/default/files/media/ECCC%20OCP%205%20June%202012%20En.pdf) និងសេចក្តីប្រកាស ព័ត៌មានរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹងចំនួនរឿងក្តីរបស់ អ.វ.ត.ក ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៤ (http://www.eccc.gov.kh/en/articles/statement-international-co-prosecutor-regarding-eccc-caseload)។

[8] នៅក្នុងករណីដែលសំណុំរឿង០០២ ត្រូវបានបំបែកបន្ថែមទៀតតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទៅលើវិសាលភាពនៃ សំណុំរឿង០០២/០២ ដែលរំពឹងថានឹងចេញនៅខែ មេសា ឆ្នាំ ២០១៤ វានឹងតម្រូវឲ្យមានសំណុំរឿង០០២/០៣។

01739798

(ii) ពេលវេលាកំណត់នៃដាក់ចម្លើយតបទៅនឹងបណ្តឹងសាទុកប្រឆាំងនឹងសាលក្រម នៅក្នុងសំណុំរឿង០០២/០១(នៅត្រីមាសទីពីរ ឆ្នាំ២០១៥)

(iii) សវនាការលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១ (ត្រឹមត្រីមាសទីពីរឆ្នាំ២០១៥)

(iv) ការចេញសាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១ ប្រសិនបើមាន(ត្រីមាសទីមួយ ឆ្នាំ២០១៦)

(v) ការបញ្ចប់សវនាការលើអង្គសេចក្តី ក្នុងសំណុំរឿង០០២/០២ (ត្រឹមត្រីមាសទីបី ឆ្នាំ២០១៦)

(vi) សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ក្នុងសំណុំរឿង០០២/០២ (ត្រីមាសទីបួន ឆ្នាំ២០១៦)

(vii) ការចេញសាលក្រមនៅក្នុងសំណុំរឿង០០២/០២ (ត្រីមាសទីបី ឆ្នាំ២០១៧)

(viii) ពេលវេលាកំណត់នៃការដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង០០២/០២ (ត្រីមាសទីបួន ឆ្នាំ២០១៧) និង

(ix) ការចេញសាលក្រមនៅក្នុងសំណុំរឿង០០២/០២ ប្រសិនបើមាន (ត្រីមាសទីពីរ ឆ្នាំ២០១៩)

១៣ នៅក្នុងសំណុំរឿង ០០៣ និង ០០៤ គ្រោងការដាច់ដោយឡែក ត្រូវបានកំណត់សម្រាប់ដំណាក់កាលស៊ើបអង្កេត ដែលនៅសេសសល់ ហើយក្នុងករណីមានការចោទប្រកាន់នោះ នឹងមានគ្រោងការបន្ថែមទៀតសម្រាប់ដំណាក់កាលជំនុំជម្រះ និងបណ្តឹងសាទុក្ខ[9]។ គ្រោងការសំខាន់សម្រាប់ដំណាក់កាលស៊ើបអង្កេតដែលនៅសេសសល់គឺ៖

[9] ដូចដែលកត់សម្គាល់ត្រង់កថាខណ្ឌទី៣៦ខាងក្រោម ដោយសាស្ថានភាពនៃកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន នៅពេលនេះយើងមិនអាចព្យាករណ៍នូវចំណុចពេលវេលាជាក់លាក់ទាក់ទិននឹងគ្រោងការជំនុំជម្រះក្តីបានឡើយ។ នៅក្នុងករណីដែលរឿងក្តី០០៣ និង០០៤ ត្រូវបញ្ជូនទៅជំនុំជម្រះ គ្រោងការនៃសវនាការលើអង្គសេចក្តីគឺអាចដូចទៅនឹងប្រការដែលមានចែងនៅក្នុងកថាខណ្ឌទី១២(v) រហូតដល់ (x) ខាងលើ ទាក់ទិននឹងសំណុំរឿង០០២/០២។

(x) សេចក្ដីជូនដំណឹងអំពីការការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ (ត្រីមាសទីមួយ ឆ្នាំ២០១៥)

(xi) សេចក្ដីជូនដំណឹងអំពីការការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៤(ត្រីមាសទីមួយ ឬត្រីមាសទីពីរ ឆ្នាំ២០១៥) ។

(xii) ការចេញដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ ជាមួយនឹងសេចក្ដីសម្រេចថាតើបញ្ជូនរឿងទៅជម្រះ ឬក៏បញ្ចប់កិច្ចនីតិវិធី (ត្រីមាសទីបី ឆ្នាំ២០១៥)។

(xiii) ការចេញដីកាដំណោះស្រាយ(១ឬច្រើន) ក្នុងសំណុំរឿង០០៤ ជាមួយនឹងសេចក្ដីសម្រេចថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី(អាស្រ័យលើថាតើសំណុំរឿងនឹងត្រូវបំបែក ឬអត់ នៅត្រីមាសទីពីរ ទីបី ឬទីបួន ឆ្នាំ២០១៥)។

(xiv) សេចក្ដីសម្រេចដោយអង្គបុរេជំនុំជម្រះ លើបណ្ដឹងឧទ្ធរណ៍ណាមួយប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ ថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះឬបញ្ចប់កិច្ចនីតិវិធីក្នុងសំណុំរឿងនោះ (ត្រីមាសទីមួយ ឆ្នាំ២០១៦ សម្រាប់សំណុំរឿង០០៣ ។ និង

(xv) សេចក្ដីសម្រេចដោយអង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ណាមួយប្រឆាំងនឹងដីកាដំណោះស្រាយមួយ(ឬច្រើន)ក្នុងសំណុំរឿង០០៤ ថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះឬបញ្ចប់កិច្ចនីតិវិធីក្នុងសំណុំរឿងនោះ(ត្រីមាសទីពីរ ឆ្នាំ២០១៦)

## II. វិធានការដែលអាចជួយបញ្ចប់ផែនការបានឆាប់រហ័ស

១៤ ដំណើរការប្រកបដោយប្រសិទ្ធិភាពរបស់អង្គជំនុំជម្រះវិសាមញ្ញ កន្លងទៅត្រូវបានរំខានដោយអសន្តិសុខផ្នែកហិរញ្ញវត្ថុដែលចេះតែបន្តកើតមាន ដែលបណ្ដាលឲ្យបុគ្គលិកចំនួនពីររូបបានបោះបង់ការងារក្នុងអំឡុងឆ្នាំ២០១៣ ព្រមទាំងបុគ្គលិកចេញចូលពីមុខតំណែងដោយមិនសមហេតុផល។ ការអនុម័តរបស់មហាសន្និបាតទៅលើឧបត្ថម្ភធនចំនួន ១៥,៥ លានដុល្លារសម្រាប់ភាគីអន្តរជាតិ នៃ អ.វ.ត.ក គឺជាវិធានការដ៏សំខាន់ដែលបានធ្វើឲ្យមានស្ថិរភាពដល់ស្ថានភាពថវិកាសម្រាប់ឆ្នាំ២០១៤ និងធ្វើឲ្យមានការផ្ដោតមូលទៅលើការធ្វើឲ្យវិវត្តទៅមុខនៃអាណត្តិតុលាការ។ នៅរយៈពេលបញ្ចប់

របាយការណ៍បច្ចុប្បន្ននេះ មហាសន្និបាតអង្គការសហប្រជាជាតិបានពន្យារពេលរហូតដល់សម័យប្រជុំ ដែលនឹងបន្តចាប់ផ្តើមនៅខែមីនា ឆ្នាំ២០១៥ ដើម្បីពិចារណាទៅលើអនុសាសន៍របស់អគ្គលេខាធិការ ស្នើឱ្យមានឧបត្ថមធនសម្រាប់ឆ្នាំ២០១៥ ដែលនឹងផ្តល់នូវស្ថេរភាពប្រហាក់ប្រហែលគ្នានៅឆ្នាំ ខាងមុខ[10]។ការអភិវឌ្ឍដ៏វិជ្ជមានមួយទៀតនៅក្នុងត្រីមាសចុងក្រោយគឺការបង្កើនវិភាគទានពីរាជរដ្ឋាភិបាលកម្ពុជា ដែលចំណាយទៅលើប្រាក់ខែបុគ្គលិកជាតិសម្រាប់ចុងត្រីមាសឆ្នាំ២០១៤ និង សន្យាចំណាយលើប្រាក់ខែបុគ្គលិកជាតិសម្រាប់ប្រាំមួយខែដំបូងនៃឆ្នាំ២០១៥។ បច្ចុប្បន្ន វានៅតែជាការសំខាន់ដែលត្រូវមានការកៀរគរថវិកាបន្ថែម ដើម្បីធ្វើឱ្យមានស្ថិរភាពដល់ភាគីអន្តរជាតិនៃ អ.វ.ត.ក។ តម្រូវការចាំបាច់នេះនឹងមានលក្ខណៈធ្ងន់ធ្ងរប្រសិនបើមហាសន្និបាតមិនអនុម័តទៅលើឧបត្ថម្ភធនសម្រាប់ឆ្នាំ២០១៥ទេនោះ។

១៥ ការប៉ាន់ស្មានលើតារាងកំណត់ពេលវេលាខាងក្រោម ត្រូវបានធ្វើឡើងដោយផ្អែកមូលដ្ឋានថា អង្គជំនុំជម្រះនិងការិយាល័យទាំងអស់មានបុគ្គលិកគ្រប់គ្រាន់ និងថាកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការនឹងមិនត្រូវរំខានបន្ថែមទៀតដោយសារតែអសន្តិសុខផ្នែកហិរញ្ញវត្ថុ។ ប្រសិនបើអសន្តិសុខផ្នែកហិរញ្ញវត្ថុនៅតែបន្ត យើងអាចចាំបាច់ត្រូវកែសម្រួលតារាងពេលវេលាឡើងវិញ។

១៦ ការប៉ាន់ស្មានលើគម្រោងបញ្ចប់ផែនការជំនុំជម្រះក្តីក្នុងសំណុំរឿង០០២/០២ បណ្តឹងសាទុក្ខលើសំណុំរឿង០០២/០១ និង ការបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង ០០៤ សន្មត់ថាសកម្មភាពទាំងអស់ កំពុងត្រូវបានធ្វើឡើងដំណាលៗគ្នា។ ក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន ក៏ដូចជាសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី នឹងចូលពាក់ព័ន្ធទាំងបណ្តឹងសាទុក្ខសំណុំរឿង០០២/០១ និងការជំនុំជម្រះក្តីសំណុំរឿង០០២/០២ នៅពេលទន្ទឹមគ្នា។ ការណ៍ដែលមេធាវីការពារក្តីបដិសេធមិនព្រមចូលរួមក្នុងសវនាការលើភស្តុតាងក្នុងសំណុំរឿង០០២/០២ ពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ បណ្តាលឱ្យមានការពន្យារពេលសវនាការជិតបីខែ។ ដើម្បីបង្ការកុំឱ្យមានបញ្ហានេះ និង ការពន្យារពេលទាក់ទិននឹងបញ្ហានេះកើតឡើងសាជាថ្មីនៅថ្ងៃអនាគត អង្គជំនុំជម្រះបានបង្គាប់តែងតាំងមេធាវីការពារក្តីប្រចាំការតំណាងឱ្យ ខៀវ សំផន និង ជំនួសមេធាវីការពារក្តីបច្ចុប្បន្ន ប្រសិនបើមេធាវីការពារក្តីបច្ចុប្បន្នបដិសេធមិនចូលរួមក្នុងកិច្ចនីតិវិធីនៅពេលអនាគត។ ទោះបីជាអង្គជំនុំជម្រះបានពិចារណាទៅលើ

[10] សំណើសុំឧបត្ថម្ភធនដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា A/69/536។

ផ្លាស់ប្តូរមេធាវីការពារក្តី ខៀវ សំផន ជាបន្ទាន់ក្តី ប៉ុន្តែអង្គជំនុំជម្រះមិនបានធ្វើដូច្នេះឡើយ ពីព្រោះថា មេធាវីការពារក្តីដែលមានគុណវុឌ្ឍិនិង ស្គាល់សំណុំរឿង មិនអាចរកបានភ្លាមទេ ហើយការជំនួស នោះទៀតសោតក៏នឹងនាំឲ្យមានការពន្យារពេលសម្រាប់ការជំនុំជម្រះក្តីកាន់តែច្រើនថែមទៀត។ សហព្រះរាជអាជ្ញានឹងចូលរួមក្នុងពេលជាមួយគ្នានៅក្នុងរឿងក្តីទាំងពីរនេះ ក្នុងចំណោមរឿងក្តីទាំងអស់ ព្រមទាំងការស៊ើបអង្កេត និង ការរៀបចំសារណាបញ្ចប់ការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០៣ និង ០០៤។ ការិយាល័យសហព្រះរាជអាជ្ញាបានស្នើសុំធនធានបន្ថែមនៅក្នុងខ្ទង់ថវិកាឆ្នាំ២០១៥ ដែលមាន ការកែប្រែ ដើម្បីធានាឲ្យប្រាកដថា ការិយាល័យសហព្រះរាជអាជ្ញាមានស្ថេរភាពក្នុងការបំពេញភារកិច្ចរបស់ខ្លួននៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២/០១ សំណុំរឿង០០២/០២ សំណុំរឿង០០៣ និង សំណុំរឿង០០៤។

១៧ សហព្រះរាជអាជ្ញាបានស្នើឲ្យមានការកែប្រែវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ ដើម្បីអនុញ្ញាតឲ្យកិច្ចស៊ើបសួរបន្តរហូតចប់ចុងចប់ដើមដោយមិនបាច់មានការស៊ើបអង្កេតលើទីតាំងប្រព្រឹត្តបទល្មើសទាំងអស់នោះទេ ល្គឹកណាទីតាំងប្រព្រឹត្តបទល្មើសដែលត្រូវបានជ្រើសរើស គឺជាតំណាងបទចោទប្រកាន់ និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនសង្ស័យដែលបានចោទឡើង។ គណៈកម្មាធិការនីតិវិធីនិងវិធានផ្ទៃក្នុង បានផ្តល់អនុសាសន៍ និងបញ្ជូនសំណើសុំធ្វើវិសោធនកម្មទៅសម័យប្រជុំពេញអង្គនៃអង្គជំនុំជម្រះវិសាមញ្ញដែលបានកំណត់យកពេលប្រជុំម្តងទៀតនៅ ពាក់កណ្តាលខែមករាឆ្នាំ ២០១៥។ ប្រសិនបើកិច្ចប្រជុំពេញអង្គអនុម័តលើសំណើសុំធ្វើវិសោធនកម្មនេះ គេរំពឹងថាវិសោធនកម្មលើវិធាន ផ្ទៃក្នុងអាចពន្លឿនការបញ្ចប់កិច្ចនីតិវិធីបានឆាប់រហ័ស។

១៨ ដើម្បីបង្កើនសមត្ថភាពស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ក្រសួងយុត្តិធម៌បានផ្តល់នីតិសម្បទាដល់មន្ត្រីច្បាប់អន្តរជាតិចំនួនប្រាំបួននាក់ ដើម្បីចុះធ្វើកំណត់ហេតុស្តាប់ចម្លើយ ហើយកិច្ចការនេះជាធម្មតាគឺត្រូវបំពេញដោយអ្នកស៊ើបអង្កេតប៉ុណ្ណោះ។ ការបង្កើនសមត្ថភាពក្នុងការចុះធ្វើកំណត់ហេតុស្តាប់ចម្លើយនេះ នឹងជំរុញឲ្យដំណាក់កាលស៊ើបសួរ បានលឿន។ ជាងនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចាប់អនុវត្តគំនិតផ្តួចផ្តើមនានា ដើម្បីបង្កើនធនធានមនុស្សរបស់ខ្លួនជាមួយនឹងបុគ្គលិកជំនាញក្រោមកម្មីដែលមិនត្រូវសងវិញ និងកម្មសិក្សាការីបន្ថែមទៀត ដើម្បីបង្កើនផលិតផលនៃកិច្ចស៊ើបសួរ។

## III. ផែនការបញ្ចប់ការស៊ើបអង្កេត

១៩ តារាងកំណត់ពេលវេលានៃការបញ្ចប់ការស៊ើបអង្កេត ត្រូវបានកំណត់ដោយកត្តានានាដូចជា៖ ប្រភេទ និងភាពស្មុគស្មាញនៃរឿងក្តី ចំនួនសាក្សីដែលត្រូវស្តាប់សក្ខីកម្ម ចំនួនបេសកម្មចុះដល់ទីកន្លែងដែលតម្រូវឲ្យមានបុគ្គលិកមានគុណវុឌ្ឍិ ការបង្អាក់ជាក់ស្តែងក្នុងការបំពេញកិច្ចស៊ើបសួរ ចំនួនញត្តិដែលដាក់ដោយភាគីនានា ថិរវេលាដែលតម្រូវដោយអង្គបុរេជំនុំជម្រះដើម្បីចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំរបស់ភាគីនានា និងការពិចារណាពាក់ព័ន្ធនានា។ ដោយមានកត្តាប្រែប្រួលទាំងនេះ ការស្មានទុកជាមុននូវតារាងកំណត់ពេលវេលាអនុវត្តគ្រោងការ អាចផ្អែកលើបទពិសោធន៍កន្លងទៅ ទាំងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ និងក្នុងស្ថាប័នតុលាការប្រហាក់ប្រហែលគ្នានេះ។

២០ វិធានផ្ទៃក្នុងដាក់បញ្ញត្តិអំពីដំណាក់កាលនីតិវិធីផ្សេងៗ ដែលសហចៅក្រមស៊ើបអង្កេតត្រូវអនុវត្តតាម ដើម្បីបំពេញឲ្យបានពេញលេញនូវដំណើរការស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេតត្រូវស៊ើបអង្កេតអង្គហេតុនានាដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដែលដាក់ដោយសហព្រះរាជអាជ្ញា។ នៅពេលបំពេញកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចនឹងបំពេញកិច្ចស៊ើបសួរ ដែលនាំឲ្យបញ្ជាក់នូវការពិត។ នៅគ្រប់ករណីទាំងអស់ ពួកគេត្រូវបំពេញកិច្ចស៊ើបសួរដោយអនាគតិ។ ភាគីនានាអាចស្នើសុំសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចស៊ើបសួរជាក់លាក់មួយចំនួន។ ការបដិសេធមិនពិចារណាលើសំណើសុំ អាចនឹងត្រូវបានប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។

២១ នៅពេលសហចៅក្រមស៊ើបអង្កេតពិចារណាឃើញថា ការស៊ើបអង្កេតត្រូវបានបញ្ចប់ សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងដល់ភាគីទាំងអស់។ ភាគីមានរយៈពេល១៥ថ្ងៃដើម្បីស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែម លើកលែងតែភាគីបោះបង់រយៈពេលនោះចោល។ ប្រសិនបើសហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធចោលសំណើបែបនេះ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាសម្រេចមួយដែលមានសំអាងហេតុ។ នៅក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីការជូនដំណឹងអំពីដីកាសម្រេចនេះ ភាគីទាំងអស់អាចដាក់បណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។ នៅពេលដែលរយៈពេលនេះបានផុតកំណត់ ត្រូវបានបោះបង់ចោល ឬបណ្តឹងឧទ្ធរណ៍ដែលបានលើកឡើងខាងលើត្រូវបានជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតត្រូវបញ្ជូនសំណុំរឿងភ្លាមៗទៅឲ្យសហព្រះរាជអាជ្ញា ដើម្បីចេញដីកាសន្និដ្ឋានស្ថាពរ។

សហព្រះរាជអាជ្ញាត្រូវចេញដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ និងបង្វិលសំណុំរឿងឲ្យសហចៅក្រមស៊ើបអង្កេត នៅក្នុងរយៈពេល៤៥ថ្ងៃ ប្រសិនបើជនត្រូវចោទត្រូវបានឃុំខ្លួន និងរយៈពេល៣ខែនៅក្នុងរឿងក្តីផ្សេងទៀត។ លើកលែងតែក្រោយពេលដំណាក់កាលដែលលើកឡើងខាងលើនេះត្រូវបានបញ្ចប់ សហចៅក្រមស៊ើបអង្កេតនឹងចេញដីកាដំណោះស្រាយថាតើត្រូវចោទប្រកាន់ជនត្រូវចោទ ដែលត្រូវបញ្ជូនរូបគាត់ទៅជំនុំជម្រះ ឬត្រូវទម្លាក់ចោលការចោទប្រកាន់។ សហព្រះរាជអាជ្ញាអាចនឹងដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយទៅអង្គបុរេជំនុំជម្រះ ចំណែកឯដើមបណ្តឹងរដ្ឋប្បវេណីអាចដាក់បណ្តឹងឧទ្ធរណ៍ តែក្នុងករណីដីកាដំណោះស្រាយបដិសេធចោលការចោទប្រកាន់ និងក្នុងករណីដែលសហព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធចោលការចោទប្រកាន់នេះ។ បន្ថែមពីលើនេះ អង្គបុរេជំនុំជម្រះបានផ្តល់នូវសិទ្ធិឲ្យជនត្រូវចោទជំទាស់នឹងធាតុផ្សំយុត្តាធិការនៅក្នុងដីកាដំណោះស្រាយតាមរយៈបណ្តឹងឧទ្ធរណ៍។ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ត្រូវតែដាក់នៅក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីការជូនដំណឹងអំពីដីកាសម្រេចនេះ។ អង្គបុរេជំនុំជម្រះអាចនឹងកែប្រែ ឬតម្កល់ដីកាដំណោះស្រាយនេះ។

២២ កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ និង ០០៤ បានចាប់ផ្តើមដំណើរការក្រោយពីការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាអន្តរជាតិនៅខែកញ្ញាឆ្នាំ២០០៩។ ដោយអនុលោមតាមវិធានផ្ទៃក្នុងនៃ អ.វ.ត.ក សហចៅក្រមស៊ើបអង្កេតបានធ្វើកំណត់ហេតុនៃការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតជាតិ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងកិច្ចស៊ើបសួរក្នុងសំណុំរឿងទាំងនេះ។ ហេតុដូចនេះ សហចៅក្រមស៊ើបអង្កេតទាំងពីររូបកំពុងតែជ្រើសរើសវិធីសាស្ត្ររៀងៗខ្លួននៅក្នុងសំណុំរឿងទាំងនេះ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិកំពុងតែស៊ើបអង្កេតយ៉ាងសកម្មលើការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅមូលដ្ឋានបទល្មើសចំនួនជាង១០ផ្សេងៗពីគ្នាក្នុងសំណុំរឿង០០៣ និងមូលដ្ឋានបទល្មើសចំនួន៥៥ក្នុងសំណុំរឿង ០០៤។ ចាប់តាំងពីសហចៅក្រមអន្តរជាតិបច្ចុប្បន្ន ចាប់ផ្តើមបំពេញភារកិច្ចនៅខែតុលា ឆ្នាំ២០១២ មក មានការបំពេញបេសកកម្មដល់ទីកន្លែងកើតហេតុ ចំនួនជាង៩០លើក និងធ្វើកិច្ចសម្ភាសន៍ជាមួយសាក្សីបានចំនួនជាង៣៥០ ។ ដើម្បីបង្កើនការយល់ដឹងអំពីកិច្ចស៊ើបសួរដែលកំពុងតែដំណើរការ ដោយផ្តោតទៅលើតួនាទីរបស់សាក្សី និង សិទ្ធិរបស់បុគ្គលស្ថិតក្រោមការស៊ើបអង្កេតនោះ ការិយាល័យសហចៅក្រម

ស៊ើបអង្កេតបានធ្វើវេទិកាសាធារណៈចំនួន៩លើកនៅអតីតមូលដ្ឋានខ្មែរក្រហម នៅអំឡុងខែវិច្ឆិកា ឆ្នាំ ២០១៤។

ពេលវេលាស្មានទុកដ៏សុក្រឹតដែលអាចផ្តល់ជូននៅបាននៅខណៈនេះ គឺ៖

(i) កិច្ចស៊ើបសួរក្នុងសំណុំ រឿង០០៣ នឹងត្រូវបញ្ចប់ ត្រឹមចុងត្រីមាសទីមួយ ឆ្នាំ ២០១៥

(ii) កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៤ នឹងត្រូវបញ្ចប់នៅត្រីមាសទីមួយ ឬទីពីរឆ្នាំ២០១៥ អាស្រ័យលើថាតើសំណុំរឿងនេះនឹងត្រូវបំបែក ឬអត់

(iii) ដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ នឹងត្រូវចេញនៅត្រីមាសទីបី ឆ្នាំ ២០១៥

(iv) ដីកាដំណោះស្រាយ(មួយឬច្រើន)ក្នុងសំណុំរឿង០០៤ នឹងត្រូវចេញនៅត្រីមាសទីពីរ ទីបី ឬទីបួន ឆ្នាំ២០១៥ អាស្រ័យលើថាតើសំណុំរឿងនេះនឹងត្រូវបំបែកឬអត់ និង

(v) រាល់បណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយនឹងត្រូវសម្រេចសេចក្តីដោយអង្គបុរេជំនុំជម្រះនៅត្រីមាសទីមួយ ឆ្នាំ២០១៦ សម្រាប់សំណុំរឿង០០៣ និងត្រីមាសទីពីរ ឆ្នាំ២០១៦ សម្រាប់សំណុំរឿង០០៤។

## IV. ផែនការបញ្ចប់សវនាការ

២៣ តារាងពេលវេលានៃការបញ្ចប់សវនាការត្រូវកំណត់ដោយកត្តានានាដូចជា៖ លក្ខណៈ និងភាពស្មុគស្មាញនៃសំណុំរឿង បញ្ហាសុខភាពរបស់ជនជាប់ចោទដែលមានវ័យចាស់ជរា ចំនួនសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលត្រូវកោះហៅ និងរយៈពេលនៃការធ្វើសក្ខីកម្មរបស់សាក្សីទាំងនោះ ការបង្អាក់ជាក់ស្តែងនានាក្នុងការបំពេញកិច្ចដំណើរការនីតិវិធី ចំនួនញត្តិដាក់ដោយភាគី និងការពិនិត្យពិច័យផ្នែករដ្ឋបាលផ្សេងៗទៀត។ ដោយមានកត្តាប្រែប្រួលទាំងនេះ ការស្មានទុកជាមុននូវតារាងកំណត់ពេលវេលាអនុវត្តគ្រោងការ គឺផ្អែកលើបទពិសោធន៍កន្លងទៅ ទាំងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ និងស្ថាប័នតុលាការប្រហាក់ប្រហែលគ្នានេះ។

01739805

២៤ ការប្រជុំរៀបចំសវនាការចំនួនមួយ ឬច្រើន តែងតែបានរៀបចំឡើងមុនពេលការចាប់ផ្ដើមសវនាការជាក់ស្ដែង។ សវនាការចាប់ផ្ដើមដោយសវនាការបឋម។ នៅក្នុងសវនាការបឋមនេះ អង្គជំនុំជម្រះសាលាដំបូង ពិចារណាទៅលើបញ្ជីសាក្សីសក្ខីភាព និងអ្នកជំនាញ ដែលដាក់ជូនដោយភាគីព្រមទាំងអញ្ញត្រកម្ម លើកឡើងដោយភាគី ហើយភាគីដើមបណ្ដឹងរដ្ឋប្បវេណីអាចផ្ដួចផ្ដើមនូវចំណុចជាក់លាក់អំពីសំណងដែលខ្លួនស្នើសុំ។ សវនាការលើអង្គសេចក្ដីចាប់ផ្ដើមដោយមានការធ្វើសេចក្ដីសន្និដ្ឋានដោយសង្ខេបពីសំណាក់សហព្រះរាជអាជ្ញា ហើយជនជាប់ចោទអាចធ្វើការឆ្លើយតបដោយសង្ខេបបាន មុនពេលអង្គជំនុំជម្រះសាលាដំបូង ចាប់ផ្ដើមតាំងសំណួរដល់ជនជាប់ចោទ ភាគីដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សី និងស្ដាប់នូវការបង្ហាញភ័ស្ដុតាង។ សហព្រះរាជអាជ្ញាមានបន្ទុកបញ្ជាក់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ដើម្បីផ្ដន្ទាទោសជនជាប់ចោទអង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿ ដោយគ្មានវិមតិសង្ស័យអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ។ ក្រោយពេលពិនិត្យភ័ស្ដុតាងទាំងអស់រួចហើយ អង្គជំនុំជម្រះស្ដាប់ការបិទកិច្ចពិភាក្សាដេញដោលពីសំណាក់ភាគី មុនពេលពិភាក្សាគ្នាជាសម្ងាត់ដើម្បីសម្រេចសេចក្ដី។ ប្រសិនបើជនជាប់ចោទត្រូវផ្ដន្ទាទោស អង្គជំនុំជម្រះសម្រេចទៅលើទោសសមស្របដែលបានកំណត់នៅក្នុងសាលក្រមរបស់ខ្លួន។ ដោយឈរលើមូលដ្ឋាននៃជំហាននីតិវិធីទាំងនេះទើបយើងកំណត់បាននូវគ្រោងការសំខាន់ៗផ្សេងៗគ្នាសម្រាប់សវនាការនីមួយៗបាន។

ក. <u>សំណុំរឿង០០២/០១</u>

២៥ សវនាការបឋមក្នុងសំណុំរឿង០០២ ប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៧ រហូតដល់ថ្ងៃ៣០ ខែមិថុនា ឆ្នាំ ២០១១។ ក្នុងខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបំបែកនូវបទចោទក្នុងសំណុំរឿង០០២ទៅជាសវនាការចំនួនពីរឬច្រើន អនុលោមទៅតាមវិធានផ្ទៃក្នុង ដែលនឹងត្រូវវិនិច្ឆ័យដោយអង្គជំនុំជម្រះទៅតាមលំដាប់លំដោយតាមការយល់ឃើញថាសមស្រប។ បទចោទនៅក្នុងសវនាការដំបូងក្នុងសំណុំរឿង០០២/០១ ផ្ដោតសំខាន់ទៅលើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទាក់ទិននឹងការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ និងទីប្រជុំជន ព្រមទាំងការសម្លាប់ទាហាន លន់ នល់ នៅទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ ភ្លាមៗក្រោយពេលខ្មែរក្រហមឡើងកាន់អំណាច ក្នុងខែមេសា ឆ្នាំ ១៩៧៥។ អង្គជំនុំជម្រះក៏បានស្ដាប់នូវការបង្ហាញភ័ស្ដុតាងទាក់ទិននឹងប្រវត្តិបក្សកុម្មុយនិស្តកម្ពុជា រចនាសម្ព័ន្ធ

ចាត់តាំងនៃកម្ពុជាប្រជាធិបតេយ្យ និងតួនាទីរបស់ជនជាប់ចោទពាក់ព័ន្ធនឹងគោលនយោបាយនៃរបប កម្ពុជាប្រជាធិបតេយ្យពាក់ព័ន្ធនឹងបទចោទទាំងអស់ក្នុងសំណុំរឿង០០២។

២៦ សវនាការលើអង្គសេចក្ដីចាប់ផ្ដើមដោយមានការធ្វើសេចក្ដីសន្និដ្ឋានដោយសង្ខេបនៅថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ២០១១។ សាក្សីចំនួន៥៨រូប ភាគីដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៣១រូប និងអ្នកជំនាញចំនួន ៣រូប បានផ្ដល់សក្ខីកម្មនៅអំឡុងពេលសវនាការ ហើយការបិទកិច្ចពិភាក្សាដេញដោលប្រព្រឹត្តទៅនៅថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០១៣។ ដូច្នេះ ដំណើរការនីតិវិធីសវនាការទាំងមូលប្រព្រឹត្តទៅអស់រយៈពេល ២២២ថ្ងៃ ។ អង្គជំនុំជម្រះសាលាដំបូង បានចេញសាលក្រមលើអង្គសេចក្ដីនៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤។

## ខ. <u>សំណុំរឿង០០២/០២</u>

២៧ នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនទៅលើបណ្ដឹងឧទ្ធរណ៍ជំទាស់ទៅនឹងការបំបែកសំណុំរឿងរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ថា សវនាការលើភ័ស្ដុតាងនៅក្នុងសំណុំរឿងទីពី(០០២) សំណុំរឿង០០២/០២ គួរតែចាប់ផ្ដើមកាន់តែឆាប់កាន់តែប្រសើរ ក្រោយពីការបិទកិច្ចពិភាក្សាដេញដោលក្នុងសំណុំរឿង០០២/០១។ អង្គជំនុំជម្រះតុលាការកំពូលក៏បានសម្រេចថាវិសាលភាពនៃសំណុំរឿង០០២/០២ ជាតំណាងឲ្យដីកាបញ្ជូនទៅជំនុំជម្រះ ដូច្នេះ តុលាការកំពូលបង្គាប់ថាអង្គជំនុំជម្រះជាអបប្បរមាគួរតែបញ្ចូលបទចោទដែលពាក់ព័ន្ធឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មន្ទីរសន្តិសុខ ស២១ នៅភ្នំពេញ សហករណ៍ចំនួនមួយ និងការដ្ឋានចំនួនមួយ[11]។

២៨ អង្គជំនុំជម្រះសាលាដំបូងបានបើកកិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃទី១១ និង ១២ ខែធ្នូ ឆ្នាំ២០១៣ ដើម្បីត្រៀមលក្ខណៈសម្រាប់សវនាការបន្ទាប់នេះ។ ក្រោយពីកិច្ចប្រជុំនេះមក អង្គជំនុំជម្រះបានចេញនូវផែនការការងារលម្អិត ហើយអញ្ជើញភាគីឲ្យដាក់សារណាស្ដីពីបទចោទដែលនឹងត្រូវបញ្ចូលទៅក្នុង

---

[11] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២ ឯកសារ E284/4/8 ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣។

សំណុំរឿង០០២/០២[12]។ សវនាការតទល់គ្នាបានធ្វើឡើងនៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ ២០១៤។ ក្នុងពេលសវនាការនេះ ភាគីបានធ្វើទឡ្ហីករណ៍ផ្ទាល់មាត់ពាក់ព័ន្ធនឹងសារណារបស់ខ្លួនអំពីវិសាលភាពនៃបទចោទ ក៏ដូចជាជំហររបស់ខ្លួនទៅលើសារណាបន្ថែមរបស់មេធាវីការពារក្តីមួយ (ខៀវ សំផន) ទាក់ទិននឹងអត្ថិភាពនៃឧបសគ្គតាមផ្លូវច្បាប់ ចំពោះការចាប់ផ្តើមសវនាការលើភ័ស្តុតាងក្នុងសំណុំរឿង ០០២/០២ រហូតដល់មានសាលក្រមស្ថាពរក្នុងសំណុំរឿង០០២/០១។ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចលើបញ្ហាទាំងពីរនេះ មុនពេលកំណត់ ក្នុងខែមីនា ឆ្នាំ២០១៤ ដោយបដិសេធនូវសារណារបស់ក្រុមមេធាវីការពារក្តី។

២៩ នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញនូវសេចក្តីសម្រេចបំបែកសំណុំរឿងថ្មីមួយទៀត ដោយកំណត់វិសាលភាពក្នុងសំណុំរឿង០០២/០២។ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា ទីតាំងបទល្មើសដែលបានចោទប្រកាន់ និងការចោទប្រកាន់តាមអង្គហេតុបង្កើតបានជាមូលដ្ឋាននៃសំណុំរឿង០០២/០២៖ អំពើប្រល័យពូជសាសន៍លើជនជាតិចាម និងជនជាតិវៀតណាម (មិនរាប់បញ្ចូលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលប្រព្រឹត្តដោយកងទ័ពបដិវត្តកម្ពុជា នៅលើទឹកដីវៀតណាម) ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងរំលោភ (ទូទាំងប្រទេស) ការបោសសម្អាតផ្ទៃក្នុង មន្ទីរសន្តិសុខ ស២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល ការដ្ឋានទំនប់១មករា ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង ការដ្ឋានទំនប់ត្រពាំងថ្មសហករណ៍នៅត្រាំកក់ ការប្រព្រឹត្តិមកលើពុទ្ធសាសនិក (កម្រិតត្រឹមតែសហករណ៍ត្រាំកក់) និងការដៅលើអតីតអ្នកមុខអ្នកការរបបសាធារណរដ្ឋខ្មែរ (ការអនុវត្តកម្រិតត្រឹមតែសហករណ៍ត្រាំកក់ ការដ្ឋានទំនប់១មករា មន្ទីរសន្តិសុខ ស២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់)[13]។ នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ អង្គជំនុំជម្រះតុលាការកំពូល តម្កល់សេចក្តីសម្រេចបំបែកសំណុំរឿងថ្មីនេះ។

៣០ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការបឋមបន្ថែមទៀតក្នុងសំណុំរឿង ០០២/០២ នៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤។ នៅក្នុងសវនាការនោះ អង្គជំនុំជម្រះសាលាដំបូង ស្តាប់សារណារបស់ភាគីទៅ

---

[12] ផែនការការងាររបស់អង្គជំនុំជម្រះសាលាដំបូងសម្រាប់សំណុំរឿង០០២/០២ និងការកំណត់កាលបរិច្ឆេទសម្រាប់ដាក់ឯកសារនាពេលខាងមុខ ឯកសារ E301/5 ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៣។

[13] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង០០២ និងវិសាលភាពនៃសំណុំរឿង០០២/០២ ឯកសារ E301/9/1 ចុះថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤។

លើលំដាប់លំដោយនៃនីតិវិធីជំនុំជម្រះបន្ថែមទៅលើសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់ខ្លួនលើវិសាលភាពនៃសំណុំរឿង០០២/០២ ហើយនិងសំណើរបស់ភាគីទាក់ទងនឹងសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលត្រូវស្តាប់សក្ខីកម្ម។ អង្គជំនុំជម្រះក៏បានផ្តល់ឱកាសដល់ដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញនូវបញ្ហាកាន់តែជាក់លាក់ថែមទៀតទៅលើសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី។

៣១ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញាជាតិនិងអន្តរជាតិ។ បន្ទាប់មក ខៀវ សំផន និង នួន ជា បានបង្ហាញភាពមិនពេញចិត្តចង់ចូលរួមក្នុង កិច្ចនីតិវិធី ក្នុងសំណុំរឿង០០២/០២ លុះត្រាតែមានដំណោះស្រាយទៅលើបញ្ហាជាក់លាក់នានា ហើយ បានបង្គាប់ឲ្យមេធាវីការពារក្តីរបស់ខ្លួនអនុវត្តទៅតាមការណែនាំរបស់ខ្លួន។ ជាពិសេស មេធាវីការពារក្តី នួន ជា ទទូចឲ្យចេញសេចក្តីសម្រេចទៅលើញត្តិរបស់ខ្លួនប្តឹងជំទាស់ចៅក្រម អង្គជំនុំជម្រះសាលាដំបូងមិនឲ្យធ្វើសវនាការលើបទចោទក្នុងសំណុំរឿង០០២/០២។ មេធាវីការពារក្តី ខៀវ សំផន ទទូចមិនឲ្យមានកិច្ចដំណើរការនីតិវិធីរហូតដល់ខ្លួនបានដាក់សារណាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសំណុំរឿង០០២/០១ ទៅអង្គជំនុំជម្រះតុលាការកំពូលជាមុនសិន ដែលត្រូវដាក់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤។ ក្រោយពីក្រុមប្រឹក្សាជំនុំជម្រះពិសេសនៃអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចបដិសេធបណ្តឹងជំទាស់អង្គជំនុំជម្រះសាលាដំបូងរួចមក មេធាវីការពារក្តី នួន ជា បានបង្ហាញខ្លួននៅចំពោះមុខតុលាការ នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤។ ក្រោយមក អង្គជំនុំជម្រះសាលាដំបូងបានខិតខំប្រឹងប្រែងម្តងហើយម្តងទៀតដើម្បីឲ្យមានការចូលរួមពីសំណាក់មេធាវីការពារក្តី ខៀវ សំផន ដោយបានចេញការព្រមានដល់មេធាវីការពារក្តី និង ចាត់តាំងមេធាវីទាំងនោះជាមេធាវីចាត់តាំងដោយតុលាការវិញម្តង។ មេធាវីការពារក្តី ខៀវ សំផន រក្សាជំហររបស់ខ្លួនដដែល ហើយអង្គជំនុំជម្រះក៏សម្រេចចិត្តបង្ខំចិត្តផ្អាកការចាប់ផ្តើមកិច្ចនីតិវិធីសវនាការលើភស្តុតាងក្នុងសំណុំរឿង០០២/០២ រហូតដល់ ថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥។

៣២ កិច្ចដំណើរការនីតិវិធីលើភស្តុតាងត្រូវបានកំណត់ ដោយអង្គជំនុំជម្រះត្រូវធ្វើសវនាការចំនួនបីថ្ងៃក្នុងមួយសប្តាហ៍។ ប្រការនេះអាចមានការកែប្រែទៅជាបួនថ្ងៃក្នុងមួយសប្តាហ៍ ដែលជាការបន្ថែមល្បឿនសវនាការ ប៉ុន្តែវាអាស្រ័យទៅលើលទ្ធផលនៃការវាយតម្លៃផ្នែកវេជ្ជសាស្ត្រ អង្គជំនុំជម្រះបង្គាប់ឲ្យធ្វើ

នៅខែមករា ឆ្នាំ២០១៥។ អង្គជំនុំជម្រះបានជម្រាបដល់ភាគីអំពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកជំនាញចំនួន២០នាក់ដំបូង ដែលខ្លួនបានជ្រើសរើសមកផ្តល់សក្ខីកម្មនៅក្នុងត្រីមាសទីមួយ ឆ្នាំ២០១៥។

៣៣ ចំនួនថ្ងៃសម្រាប់បើកនិងបញ្ចប់សវនាការពេញលេញ គឺអាចស្មានទុកបានក្នុងសំណុំរឿង ០០២/០២ តែនៅពេល ចំនួនទូទៅនៃសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលត្រូវកោះហៅ មានការកំណត់ច្បាស់លាស់ហើយដោយអង្គជំនុំជម្រះសាលាដំបូង។ សក្ខីកម្មសរុបចំនួន ២៧២ ត្រូវបានស្នើឡើងដោយភាគី។ ការស្មានទុកពេលទាក់ទិននឹងសំណុំរឿង០០២/០២ គឺផ្អែកទៅលើការសន្មតថាសវនាការទីពីរនឹងមានលក្ខណៈស្មុគស្មាញ និងត្រូវការពេលវេលាដូចគ្នានឹងសវនាការទីមួយដែរ ប៉ុន្តែអាចខុសប្លែកពីគ្នាច្រើន នៅពេលដែលកត្តានេះត្រូវបានកំណត់ពេញលេញ។ បន្ទាប់ពីការបើកសវនាការលើភស្តុតាងជាថ្មី អង្គជំនុំជម្រះក៏នឹងមានលទ្ធភាពផងដែរក្នុងវាយតម្លៃផលប៉ះពាល់កើតចេញពីការពន្យារពេលការជំនុំជម្រះក្តី ដោយសាមេធាវីការពារក្តីបដិសេធមិនចូលរួមក្នុងកិច្ចនីតិវិធីជាមួយនឹងគ្រោងការសំខាន់ៗដែលរំពឹងទុកសម្រាប់ឆ្នាំ២០១៦។

៣៤ ចំពោះកត្តានានាដែលអាចទាក់ទិននឹងរយៈពេលនៃជំនុំជម្រះដែលស្មានទុក ដែលអាចនឹងកើតឡើងនៅថ្ងៃអនាគត ការកំណត់សម្រេចណាមួយរបស់អង្គជំនុំជម្រះសាលាដំបូងដោយពិចារណាទៅលើស្ថានភាពសុខភាពរបស់ជនជាប់ចោទ ទាក់ទិននឹងការកាត់បន្ថយចំនួនថ្ងៃសវនាការក្នុងមួយ សប្តាហ៍ និង/ឬរយៈពេលនៃថ្ងៃមានសវនាការ នឹងមានផលប៉ះពាល់ដោយផ្ទាល់។ នីតិវិធីបណ្តឹងសាទុក្ខ ប្រឆាំងសាលក្រមសំណុំរឿង០០២/០១ ដូចជាសវនាការ ឬសារណាបន្ថែមជាដើម ក៏អាចប៉ះពាល់ថែមទៀតទៅលើវត្តមានរបស់ភាគីក្នុងការចូលរួមសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង០០២/០២ ដែលកំណត់កាលបរិច្ឆេទដូចគ្នាសំណុំរឿង០០២/០១ក៏អាចមានផលប៉ះពាល់ដល់ភាពទំនេររបស់ភាគី ក្នុងការចូលរួមសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង០០២/០២ផងដែរ។

## គ. <u>បទចោទដែលនៅសេសសល់/ការចោទប្រកាន់តាមអង្គហេតុក្នុងសំណុំរឿង០០២</u>

៣៥ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ អង្គជំនុំជម្រះតុលាការកំពូលប្រកាសផ្អាកដំណើរការនីតិវិធីពាក់ព័ន្ធនឹងបទចោទដែលនៅសល់ ដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០១ និង ០០២/០២ ដោយរង់ចាំសេចក្តីសម្រេចសមស្រប របស់អង្គជំនុំជម្រះសាលា

ដំបូង[14]។ អង្គជំនុំជម្រះតុលាការកំពូលលើកឡើងម្តងទៀតថាអង្គជំនុំជម្រះសាលាដំបូងមានករណីកិច្ច កាត់សេចក្តី ឬចេញសេចក្តីសម្រេចទៅលើបទចោទដែលនៅសល់ក្នុងសំណុំរឿង០០២ អនុលោមតាម ក្រមខណ្ឌគតិយុត្តិ និងជំរុញឲ្យអង្គជំនុំជម្រះសាលាដំបូងអនុវត្តទៅតាមករណីកិច្ចនេះ។

## ឃ. <u>សំណុំរឿង០០៣ និង សំណុំរឿង០០៤</u>

៣៦ លុះត្រាតែមានសេចក្តីសម្រេចថាតើ សំណុំរឿង០០៣ និង/ឬ០០៤ ត្រូវបញ្ជូនទៅជំនុំជម្រះ ទើបអាច ធ្វើការស្មានទុកបានទៅលើរយៈពេលសម្រាប់បញ្ចប់ការជំនុំជម្រះក្តីទាំងនេះបាន។ ការវាយតម្លៃលើ ពេលវេលាដែលតម្រូវ អាចផ្អែកទៅលើចំនួនចុងចោទ ក៏ដូចជាចំនួន និងភាពស្មុគស្មាញនៃអង្គហេតុ និងអង្គច្បាប់នៃបទចោទ និងទីតាំងប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅ ជំនុំជម្រះ។

## V. ផែនការបញ្ចប់បណ្តឹងសាទុក្ខ

៣៧ ដើម្បីធ្វើការប៉ាន់ស្មានអំពីរយៈពេលសម្រាប់ដំណើរការនីតិវិធីបណ្តឹងសាទុក្ខ ត្រូវតែញែកឲ្យបានច្បាស់ អំពីដំណាក់កាលបណ្តឹងសាទុក្ខ ដូចតទៅ៖ ដំណាក់កាលទីមួយ គឺត្រូវការពេលវេលាសម្រាប់ដាក់ សារណារបស់ភាគីទាំងអស់។ អនុលោមតាមវិធានផ្ទៃក្នុង ភាគីត្រូវដាក់សេចក្តីជូនដំណឹងពីបណ្តឹង សាទុក្ខក្នុងរយៈពេល៣០ ថ្ងៃក្រោយពីការប្រកាសសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ ក្នុង ករណីដែលមានបណ្តឹងសាទុក្ខ ដោយភាគីណាមួយ ភាគីដទៃទៀតមានរយៈពេលបន្ថែម១៥ ថ្ងៃទៀត ដើម្បីដាក់សេចក្តីសុំប្តឹងសាទុក្ខ។ វិធានផ្ទៃក្នុងចែងថាម្ចាស់បណ្តឹងសាទុក្ខត្រូវដាក់ជូនសារណាបណ្តឹង សាទុក្ខក្នុងរយៈពេល ៦០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងពីការប្តឹងសាទុក្ខ។ ភាគីនឹងមាន រយៈពេល១០ថ្ងៃក្នុង ការដាក់ចម្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ភាគីដទៃទៀត។ ប៉ុន្តែ កាលពីពេលកន្លងទៅ អង្គជំនុំជម្រះបានផ្តល់ជូនរយៈពេលបន្ថែមសមរម្យសម្រាប់ដាក់ចម្លើយតប។ ក្នុងអំឡុងពេលនេះ អង្គជំនុំជម្រះតុលាការកំពូលនឹងស្រាវជ្រាវទៅលើបញ្ហាច្បាប់ និងអង្គហេតុដែល

---

[14] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការ បំបែកកិច្ចនីតិវិធីបន្ថែមលើសំណុំរឿង០០២ និង វិសាលភាពនៃសំណុំរឿង០០២/០២ ឯកសារ E301/9/1/13 ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤។

ពាក់ព័ន្ធ ដើម្បីរៀបចំខ្លួនពេញលេញសម្រាប់សវនាការលើបណ្តឹងសាទុក្ខដែលជាដំណាក់កាលទីពីរ។ សវនាការលើបណ្តឹងសាទុក្ខអាចត្រូវបានបង្គាប់ នៅពេលណាភាគីបានដាក់សារណាទាំងអស់របស់ខ្លួន និងពិនិត្យដោយអង្គជំនុំជម្រះតុលាការកំពូលរួចហើយសិន។ ដំណាក់កាលទីបី គឺការពិភាក្សាសម្រេចក្រោយពេលសវនាការនោះ និងការរៀបចំចេញសាលដីកាលើបណ្តឹងសាទុក្ខ។

## ក. សំណុំរឿង០០២/០១

៣៨ តាមសំណើរបស់ក្រុមមេធាវីការពារក្តី អង្គជំនុំជម្រះតុលាការកំពូលបានពន្យារពេលកំណត់ដាក់ការជូនដំណឹងអំពីបណ្តឹងសាទុក្ខលើសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង០០២/០១ ចំនួន២១ថ្ងៃបន្ថែមទៀត រហូតដល់ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤[15]។ ក្រុមមេធាវីទាំងពីរបានជូនដំណឹងអំពីបណ្តឹងសាទុក្ខទាន់ពេលកំណត់ ហើយបានពង្រឹងមូលដ្ឋានបណ្តឹងសាទុក្ខចំនួន២២៣ (មេធាវីការពារក្តី នួន ជា) និង ១៤៨(មេធាវីការពារក្តី ខៀវ សំផន) ដែលក្តោបស្ទើរតែទាំង អស់ទៅលើសំអាងហេតុនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២/០១ ព្រមទាំងសេចក្តីសម្រេចនានារបស់អង្គជំនុំជម្រះសាលាដំបូង ដែលមិនត្រូវអនុញ្ញាតឲ្យប្តឹងសាទុក្ខភ្លាមៗ រហូតដល់ចេញសាលក្រមលើអង្គសេចក្តី[16]។ មិនតែប៉ុណ្ណោះ សហព្រះរាជអាជ្ញាក៏បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខដែលស្នើសុំត្រឹមតែការបំភ្លឺបញ្ជាក់ពីអង្គជំនុំ ជម្រះតុលាការកំពូលទាក់ទិននឹងការអនុវត្តទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួមដែលគេហៅថា "សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣"[17]។ តាមសំណើរបស់ក្រុមមេធាវីការពារក្តី និង សហព្រះរាជអាជ្ញា នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ អង្គជំនុំជម្រះតុលាការកំពូល បានអនុញ្ញាតឲ្យក្រុមមេធាវីការពារក្តីដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួនមិនឲ្យហួសពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ពោលគឺ៩០ថ្ងៃក្រោយពេលជូនដំណឹងស្តីពីបណ្តឹងសាទុក្ខ

[15] សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំពន្យារពេល និងបន្ថែមចំនួនទំព័រលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសារណានៃបណ្តឹងសាទុក្ខ ឯកសារ F3/3 ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤។

[16] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាស្តីពីបណ្តឹងសាទុក្ខចំពោះសេចក្តីសម្រេចនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ E313/3/1 ចុះថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០១៤។ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីលោក ខៀវ សំផន ប្រឆាំងនឹងសាលក្រមលើសំណុំរឿង ០០២/០១ ឯកសារ E313/2/1 ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤។

[17] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាស្តីពីបណ្តឹងសាទុក្ខចំពោះសេចក្តីសម្រេចនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ E313/3/1 ចុះថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០១៤។

ជាភាសាអង់គ្លេស ឬ ភាសាបារាំង ហើយសហព្រះរាជអាជ្ញានឹងត្រូវដាក់ចម្លើយតបរួមមិនឲ្យហួសពី ២៨០ទំព័រ ដែលត្រូវដាក់ក្នុងរយៈពេល៣០ថ្ងៃការដាក់សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី សំណៅភាសាខ្មែរ ដែលជូនដំណឹងក្រោយគេបំផុត[18]។ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់ការពន្យារពេលដល់សហព្រះរាជអាជ្ញាពុំបានផ្តល់ការពន្យារពេលដល់សហព្រះរាជអាជ្ញាក្នុងការដាក់សារណាបណ្តឹងសាទុក្ខឡើយ[19] ដែលត្រូវដាក់នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤[20]។ អង្គជំនុំជម្រះតុលាការកំពូលបាន ផ្តល់ការបន្ថែមចំនួន៦០ទំព័រដល់មេធាវីការពារក្តី នួន ជា ដើម្បីដាក់សារណាបណ្តឹងសាទុក្ខ (ចំណែក មេធាវីការពារក្តី ខៀវ សំផន ពុំបានដាក់សំណើសុំបន្ថែមចំនួនទំព័រឡើយ)និងការពន្យារពេលដល់ក្រុម មេធាវីការពារក្តីទាំងពីរក្រុម ដើម្បីដាក់ចម្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ៣០ ថ្ងៃក្រោយពេលដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន ពោលគឺមិនឲ្យហួសពីថ្ងៃទី២៨ ខែមករាឆ្នាំ ២០១៥[21]។ នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៤ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់តាមសំណើសុំដោយ ផ្នែករបស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលទទួលស្គាល់សិទ្ធិរបស់ពួកគេក្នុងការដាក់ ចម្លើយតបរួមទៅនឹងផ្នែកមួយចំនួនតូចនៃបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ក្នុងរយៈពេល៣០ថ្ងៃក្រោយសហព្រះរាជអាជ្ញាដាក់ចម្លើយតប។ ផ្អែកលើការគ្រោងទុកបច្ចុប្បន្នទៅលើការបកប្រែ សារណាបណ្តឹងសាទុក្ខ មានការប៉ាន់ស្មានថា កាលកំណត់ចុងក្រោយដាក់ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅលើសារណាបណ្តឹងសាទុក្ខ គឺចុងខែមីនា ឆ្នាំ២០១៥ ហើយកាលបរិច្ឆេទចុងក្រោយនៃចម្លើយ តបរបស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីគឺនៅចុង ខែមេសា ឆ្នាំ២០១៥។ គេរំពឹងទុកថា អង្គជំនុំជម្រះតុលាការកំពូលអាចតម្រូវឲ្យមាន សវនាការបណ្តឹងសាទុក្ខ

---

[18] សេចក្តីសម្រេចលើសំណើសុំពន្យាររយៈពេល និងបន្ថែមចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខ និងសារណាតប ឯកសារ F9 ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ("សេចក្តីសម្រេចលើការសុំពន្យាររយៈពេល និងបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងសាទុក្ខ") កថាខណ្ឌ ២៣។

[19] សេចក្តីសម្រេចលើការសុំពន្យាររយៈពេល និងបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងសាទុក្ខ កថាខណ្ឌ ១៤។

[20] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១ ឯកសារ F11 ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤។

[21] សេចក្តីសម្រេចលើសំណើរបស់មេធាវការពារក្តីសុំបន្ថែមចំនួនទំព័រ ដើម្បីប្តឹងសាទុក្ខ និងបន្ថែមពេលវេលាដើម្បីដាក់សារណាតប ឯកសារ F13/2 ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៤។

ដោយសារភាពស្មុគស្មាញ និង វិសាលភាពនៃបណ្តឹងសាទុក្ខ ហើយសវនាការលើបណ្តឹងសាទុក្ខត្រូវបានប៉ាន់ស្មាននឹងធ្វើឡើងនៅ ចុងត្រីមាសទីពីរ ឆ្នាំ២០១៥។

៣៩ វាជាការពិបាកក្នុងការព្យាករណ៍ឲ្យបានត្រឹមត្រូវទាក់ទិននឹងរយៈពេលនៃនីតិវិធីបណ្តឹងសាទុក្ខមុនពេលមានសារណាបណ្តឹងសាទុក្ខពេញលេញត្រូវបានធ្វើឡើង ដែលគេរំពឹងថានឹងស្ថិតក្នុងត្រីមាសទីមួយ ឆ្នាំ២០១៥ ជាមួយនឹងការដាក់សារណាឆ្លើយតប។ ហេតុដូច្នេះ ការព្យាករណ៍បច្ចុប្បន្ន នេះគឺផ្អែកលើការសន្និដ្ឋានថា មូលដ្ឋានបណ្តឹងសាទុក្ខទាំងអស់នៅក្នុងសារណាបណ្តឹងសាទុក្ខ ក្នុងនោះរួមមានបណ្តឹង សាទុក្ខលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមិនអាចលើកឡើងជាបណ្តឹងបន្ទាន់បង្ខំពេលកិច្ចដំណើរការនីតិវិធីជំនុំជម្រះក៏ដូចជាការរំលោភសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលត្រូវបានចោទឡើង។ ការគ្រោងទុកនានាក៏ផ្អែកទៅលើញត្តិចំនួនបីផ្សេងៗគ្នាសម្រាប់ភស្តុតាងបន្ថែមទៅលើបណ្តឹងសាទុក្ខដែលបានដាក់រួចហើយដោយមេធាវីការពារក្តី នួន ជា ចាប់តាំងពីការចេញសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២/០១[22]។ ប៉ុន្តែផលប៉ះពាល់ពេញលេញនៃញត្តិទាំងនេះមិនអាចវាយតម្លៃបានដោយគ្មានការកំណត់ពេញលេញទៅលើសារណាបណ្តឹងសាទុក្ខនោះឡើយ។

៤០ ដោយពិចារណាទៅលើកត្តាទាំងនេះ និង យុត្តិសាស្ត្រដែលពាក់ព័ន្ធសម្រាប់រឿងក្តីដែលមាន ទំហំ និង ភាពស្មុគស្មាញប្រហាក់ប្រហែលគ្នា ការប៉ាន់ស្មានដ៏ត្រឹមត្រូវបំផុតដែលអាចផ្តល់បាននៅពេលនេះគឺថាដំណើរការបណ្តឹងសាទុក្ខអាចនឹងត្រូវបញ្ចប់នៅត្រីមាសទីមួយឆ្នាំ២០១៦។ ខែបន្ទាប់ៗទៀតនឹងពាក់ព័ន្ធនឹងការពិនិត្យទៅលើការដាក់ឯកសារទាំងអស់ រួចហើយមានការរៀបចំ និង ធ្វើសវនាការបណ្តឹងសាទុក្ខ។ បន្ទាប់មកអង្គជំនុំជម្រះតុលាការកំពូលនឹងបញ្ចប់ការពិភាក្សាសម្រេច និង រៀបចំចេញសាលដីកាក្នុងសំណុំរឿង០០២/០១។

---

[22] សំណើសុំឲ្យទទួល និងពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ F2 ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤។ សំណើទីពីរស្នើសុំឲ្យពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ F2/1 ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៤។ សំណើលើកទីបីស្នើសុំឲ្យធ្វើការពិចារណា និងទទួលយកភស្តុតាងបន្ថែមទាក់ទងបណ្តឹងសាទុក្ខប្រឆាំងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១ F2/4 ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៤ (សម្ងាត់បំផុត)។

៤១ សម្រាប់សំណុំរឿង០០២/០២ ដោយផ្អែកលើការព្យាករណ៍បច្ចុប្បន្នរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថាការជំនុំជម្រះដំណាក់កាលទីពីរទំនងជានឹងមានលក្ខណៈស្មុគស្មាញ និងត្រូវការពេលវេលាច្រើនដូច ជាការជំនុំជម្រះដំណាក់កាលទីមួយនោះ អង្គជំនុំជម្រះតុលាការកំពូលក៏ព្យាករណ៍ស្រដៀងគ្នានេះដែរនៅពេលនេះដែលថាបណ្ដឹងសាទុក្ខទីពីរនឹងមានលក្ខណៈស្មុគស្មាញនិងត្រូវការពេលវេលាច្រើន ដូចគ្នានឹងបណ្ដឹងសាទុក្ខទី១ និង កត្តានានាផងដែរ ដូចជាសំណើសុំ ពន្យារពេលក្នុងការដាក់សារណាឬញត្តិ ដើម្បីស្នើដាក់ជូនភស្តុតាងបន្ថែម អាចប៉ះពាល់ដល់រយៈពេលនៃដំណើរការនីតិវិធីបណ្ដឹងសាទុក្ខ ហើយនឹងត្រូវការគិតបញ្ចូលទៅក្នុងការរៀបចំផែនការ ក្រោយពេលមានការដាក់បណ្ដឹងសាទុក្ខផងដែរ។

៤២ ជាងនេះទៅទៀត បណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២/០២ ត្រូវតែសម្រេចក្នុងរយៈពេលបីខែជាកំណត់។ ផ្អែកលើបទពិសោធន៍ពីសំណុំរឿង០០២/០១ គិតជាមធ្យម រំពឹងថាមានបណ្ដឹងសាទុក្ខភ្លាមៗចំនួនមួយក្នុងមួយខែក្នុងរយៈពេលមាននីតិវិធីសវនាការ។ ប្រការនេះអាចធ្វើឲ្យមានតម្រូវការធនធានរបស់អង្គជំនុំជម្រះតុលាការកំពូលកាន់តែធំឡើង ហើយប៉ះពាល់ដល់តារាងកំណត់ពេលវេលាសម្រាប់ការចេញសាលដីកាលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង០០២/០១។

## VI. សេចក្ដីសន្និដ្ឋាន

៤៣ សម្រាប់ឆ្នាំ ២០១៥ កិច្ចដំណើរការនីតិវិធីបណ្ដឹងសាទុក្ខក្នុងសំណុំរឿង០០២/០១ និង នីតិវិធីជំនុំជម្រះក្ដីក្នុងសំណុំរឿង០០២/០២ នឹងបន្តស្របគ្នារហូតពេញមួយឆ្នាំ។សម្រាប់សំណុំរឿង០០២/០១ រំពឹងថានឹងសម្រេចបាននូវគ្រោងការចំនួន២ថែមទៀតគឺ(i) ការដាក់ចម្លើយតបទៅនឹងសារណាបណ្ដឹងសាទុក្ខ និង (i) ការបញ្ចប់សវនាការបណ្ដឹងសាទុក្ខ។ រំពឹងថានឹងបញ្ចប់បានគ្រោងការសំខាន់ចំនួនមួយទាក់ទិន នឹងនៅក្នុងសំណុំរឿង០០២ពោលគឺ ការចាប់ផ្ដើមសវនាការលើ ភស្តុតាងក្នុង នៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥។ មានការរំពឹងថានឹងសម្រេចបាននូវគ្រោងការថ្មីចំនួនបួនពោលគឺទាក់ទិននឹងសំណុំរឿង០០៣ និង ០០៤ (i) សេចក្ដីជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរ ក្នុងសំណុំរឿង០០៣ (ii) សេចក្ដីជូនដំណឹងអំពីការ បញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង០០៤។ (iii) ការចេញដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៣ ជាមួយនឹងសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតថាតើត្រូវបញ្ជូនសំណុំ

រឿងទៅជំនុំជម្រះ ឬ បញ្ចប់កិច្ចនីតិវិធីតែម្តង។ (iv) ការចេញដីកាដំណោះស្រាយមួយ(ច្រើន)ក្នុងសំណុំរឿង០០៤ ជាមួយនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតថាតើត្រូវបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ឬបញ្ចប់កិច្ចនីតិវិធី។

៤៤ សម្រាប់ឆ្នាំ២០១៦ មានការរំពឹងថានឹងសម្រេចបាននូវគ្រោងការចំនួនបីក្នុងសំណុំរឿង០០២/០១ និងសំណុំរឿង០០២/០២ គឺ៖ (i) ការចេញសាលដីកាលើបណ្តឹងសាទុក្ខលើសំណុំរឿង០០២/០១ (ii) ការបញ្ចប់សវនាការលើអង្គសេចក្តី/ភ័ស្តុតាងក្នុង សំណុំរឿង០០២/០២ និង(iii) ការចេញសេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោលក្នុងសំណុំរឿង ០០២/០២។ ចំពោះសំណុំរឿង០០៣ និង ០០៤ រំពឹងថានឹងសម្រេចបានគ្រោងការសំខាន់ចំនួនពីរគឺ (i) ការសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៣ និង (ii) ការសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤ ជាមួយនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះថាតើត្រូវបញ្ជូនសំណុំរឿងទាំងនេះទៅជំនុំជម្រះឬបញ្ចប់កិច្ចនីតិវិធី។ ក្នុងករណីដែលសំណុំរឿងណាមួយ ឬសំណុំរឿងទាំងពីរ ត្រូវបានបញ្ជូនទៅជំនុំជម្រះទាំងមូល ឬដោយផ្នែក ការព្យាករណ៍ទុកនូវតារាងកំណត់ពេលវេលាក្នុងសំណុំរឿងទាំងនេះគឺអាចយកមកវាយតម្លៃបាន។

៤៥ សម្រាប់ឆ្នាំ ២០១៧ មានការរំពឹងថានឹងសម្រេចបាននូវគ្រោងការចំនួនពីរ គឺ៖ (i) ការចេញសាលក្រមលើសំណុំរឿង០០២/០២ និង (ii) ពេលវេលាកំណត់សម្រាប់ដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង០០២/០២។

៤៦ ក្នុងអំឡុងឆ្នាំ ២០១៨ អង្គជំនុំជម្រះតុលាការកំពូលនឹងជាប់រវល់ធ្វើសវនាការបណ្តឹងសាទុក្ខ និងការពិភាក្សាសម្រេច ក្នុងករណីដែលមានបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង។

៤៧ សម្រាប់ឆ្នាំ២០១៩ មានការរំពឹងថានឹងសម្រេចបាននូវគ្រោងការចំនួនមួយ គឺ ៖ (i) ការចេញសាលដីកាលើសំណុំរឿង០០២/០២។

៤៨ ការស្មានទុកនូវគ្រោងការនានាដែលរៀបរាប់ខាងលើនេះ មានសង្ខេបជូនក្នុងតារាងដែលភ្ជាប់ជូនជាមួយនឹងផែនការនេះស្រាប់។

01739816




(ក) កាលបរិច្ឆេទកំណត់សម្រាប់ឆ្លើយតបទៅនឹងសារណាបណ្ដឹងសាទុក្ខ

(ខ) សវនាការលើបណ្ដឹងសាទុក្ខ

(គ) សាលដីកា




(ឃ) ការចាប់ផ្ដើមសវនាការពិនិត្យភស្តុតាង

(ង) ការបញ្ចប់សវនាការលើអង្គសេចក្ដី

(ច) សេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាវេញដោល

(ឆ) សាលក្រម

(ជ) កាលបរិច្ឆេទកំណត់សម្រាប់បណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រម

(ឈ) សាលដីកា




(ញ) ការជូនដំណឹងអំពីការបញ្ចប់ការស៊ើបអង្កេត

(ដ) ដីកាដំណោះស្រាយ កសចស

(ឋ) សេចក្ដីសម្រេចរបស់ អបជ ទៅលើដីកាដំណោះស្រាយ




(ឌ) ការជូនដំណឹងអំពីការបញ្ចប់ការស៊ើបអង្កេត។ ពេលវេលាកំណត់អាស្រ័យទៅលើថាតើ សំណុំរឿងនឹងត្រូវបានបំបែកឬទេ។

(ឍ) ដីកាដំណោះស្រាយ កសចស។ ពេលវេលាកំណត់អាស្រ័យទៅលើថាតើ សំណុំរឿងនឹងត្រូវបានបំបែកឬទេ។

(ណ) សេចក្ដីសម្រេចរបស់ អបជ ទៅលើដីកាដំណោះស្រាយ